# សេចក្តីថ្លែងការណ៍រួម

នេះគឺជាសេចក្តីថ្លែងការណ៍រួមរវាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត ភីអិលស៊ី (អម្រឹត) និងដើមបណ្តឹង ពាក់ព័ន្ធនឹងការវិនិយោគរបស់ស្ថាប័ន IFC នៅក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត ភីអិលស៊ី ("អម្រឹត") (គម្រោង IFC៖ Amret MFI Equity 34748)។ បណ្តឹងនេះត្រូវបានសម្គាល់ថាជា "Cambodia MIFA Debt Fund Amret MFI Equity 13" ។

ក្នុងអំឡុងពេលដំណាក់កាលវាយតម្លៃរបស់ CAO ដើមបណ្តឹង និងអតិថិជនរបស់ IFC គឺ អម្រឹត បានបង្ហាញការចាប់អារម្មណ៍ចូលរួមក្នុងដំណើរការដោះស្រាយវិវាទ ដែលសម្របសម្រួលដោយ CAO ដើម្បីដោះស្រាយបញ្ហាដែលបានលើកឡើងនៅក្នុងបណ្តឹងពាក់ព័ន្ធនឹងអម្រឹត ដោយប្រើប្រាស់វិធីសាស្ត្របែបសហការ។ ភាគីទាំងពីរបានព្រមព្រៀងលើបទបញ្ជាផ្ទៃក្នុង សម្រាប់កិច្ចប្រជុំសម្រុះសម្រួល កាលពីខែធ្នូ ឆ្នាំ២០២៥។

ជាលទ្ធផលនៃការចូលរួមដោះស្រាយវិវាទដោយស្ម័គ្រចិត្ត ភាគីទាំងពីរបានឈានដល់ការចុះហត្ថលេខាលើកិច្ចព្រមព្រៀង នៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០២៦ និងបានព្រមព្រៀងឱ្យ CAO ពិនិត្យតាមដានលើការអនុវត្តកិច្ចព្រមព្រៀងនេះ រយៈពេល ២៧ ខែ រហូតដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៨ និងអាចបន្ថែមពេលទៀតបាន ។

លើសពីនេះ ភាគីទាំងពីរ រួមជាមួយនឹងតំណាងរៀងៗខ្លួន បានព្រមព្រៀងរក្សាការសម្ងាត់នូវខ្លឹមសារនៃកិច្ចព្រមព្រៀង ដើម្បីគោរពដល់ឯកជនភាពនៃដំណើរការ ការពារព័ត៌មានសើបផ្នែកពាណិជ្ជកម្ម និងមានការយោគយល់គ្នាទៅវិញទៅមក។

Official Use Only